STATE OF WASHINGTON
DEPARTMENT OF SOCIAL AND HEALTH SERVICES
DIVISION OF CHILD SUPPORT (DCS)

# សិទ្ធិ និងការទទួលខុសត្រូវរបស់ឪពុក/ម្តាយមិនមែនជាអ្នកគ្រប់គ្រងកូន
# Noncustodial Parent’s Rights and Responsibilities

នាយកដ្ឋានឧបត្ថម្ភក្មេង (DCS)៖

1. បង្កើតសំណុំរឿង និងអនុវត្តទាមទារការឧបត្ថម្ភតាមដីកាឧបត្ថម្ភក្មេង ។ បង្កើតសំណុំរឿង និងអនុវត្តកាតព្វកិច្ចឧបត្ថម្ភវេជ្ជសាស្ត្រ ។
2. ពិនិត្យដីកាឧបត្ថម្ភក្មេងនានាសំរាប់លទ្ធភាពធ្វើកំណែប្រែ ។
3. ទទួល កត់ត្រាបញ្ជី និងចែកចាយប្រាក់បង់ឧបត្ថម្ភក្មេងតាមរយៈការិយាល័យចុះបញ្ជីការប្រាក់ឧបត្ថម្ភរដ្ឋវ៉ាស៊ីនតោន (WSSR) ។

## ឪពុក/ម្តាយមិនមែនជាអ្នកគ្រប់គ្រងកូន

អ្នកជាឪពុក/ម្តាយមិនមែនជាអ្នកគ្រប់គ្រងកូនម្នាក់ ។ ឪពុក/ម្តាយមិនមែនជាអ្នកគ្រប់គ្រងកូនគឺជាឪពុកបង្កើត ឬអ្នកត្រូវបានទទួលស្គាល់ ឬវិនិច្ឆ័យថាជាឪពុក ចុង ម្តាយបង្កើត ឬ អ្នកត្រូវបានវិនិច្ឆ័យថាជាម្តាយចុងដែលត្រូវតែផ្តល់ការឧបត្ថម្ភផ្នែកហិរញ្ញវត្ថុសំរាប់កូនៗនៅក្រោមបន្ទុក ។ ច្បាប់រដ្ឋ និងច្បាប់សហព័ន្ធ ដាក់បន្ទុកនូវភារៈកិច្ចនេះ ។

## ការបង់ប្រាក់ឧបត្ថម្ភក្មេង

ធម្មតា អ្នកត្រូវតែបង់ប្រាក់ឧបត្ថម្ភកូន ។  ក្រោយពី DCS ប្រគល់ជូនជាផ្លូវការនូវសេចក្តីជូនដំណឹងតំរូវឲ្យអ្នកបង់ប្រាក់ឧបត្ថម្ភក្មេង DCS នឹងមិនផ្តល់ឥណទានគណនីរបស់អ្នកសំរាប់តែប្រាក់បង់ទាំងឡាយណាដែលបានផ្ញើទៅនរណាផ្សេងក្រៅពី WSSR  ទៅតុលាការរដ្ឋណាមួយផ្សេងទៀត ឬទីភ្នាក់ងារឧបត្ថម្ភក្មេង ឬតុលាការកុលសម្ព័ន្ធ ឬតុលាការរដ្ឋ ឬ ទីភ្នាក់ងារឧបត្ថម្ភក្មេងមួយទៀត ។ DCS នឹងមិនផ្តល់ឥណទានគណនីរបស់អ្នកសម្រាប់ប្រាក់ដែលបានបង់ផ្ទាល់ទៅភាគីផ្សេងទៀតនៃដីកាឧបត្ថម្ភ លុះត្រាតែប្រាក់ត្រូវបានបង់ពីទីភ្នាក់ងារសម្រាប់ផលប្រយោជន៍បន្ទុក ដូចជារដ្ឋបាលសន្តិសុខសង្គម ក្រសួងពលកម្ម និងឧស្សាហកម្ម ឬក្រសួងមុខងារអតីតយុទ្ធជនសម្រាប់គោលបំណងកាតព្វកិច្ចឧបត្ថម្ភក្មេង ។

1. សូមប្រាប់ DCS ជាបន្ទាន់ បើទីភ្នាក់ងារឧបត្ថម្ភកុមាររបស់រដ្ឋឬកុលសម្ព័ន្ធ ឬតុលាការរបស់រដ្ឋឬកុលសម្ព័ន្ធ ឬតុលការដទៃទៀតសុំឲ្យអ្នក ឲ្យបង់ប្រាក់ឧបត្ថម្ភទៅឲ្យពួកគេ។
2. កុំផ្ញើប្រាក់បង់នោះទៅនរណាម្នាក់ផ្សេងទៀតក្រៅពីអាសយដ្ឋានសំរាប់ WSSR ដែលចុះនៅខាងក្រោម លុះត្រាតែ DCS ប្រាប់អ្នកជាលាយ លក្ខណ៏អក្សរ ថាយើងបិទសំណុំរឿងរបស់អ្នក ។

អ្នកត្រូវតែបង់ប្រាក់ឧបត្ថម្ភកូនទាំងអស់ទៅឈ្មោះ Washington State Support Registry (WSSR)។ អ្នកអាចបង់ប្រាក់ទាំងនេះទៅតាមមធ្យោបាយណាមួយខាងក្រោមនេះ ៖

1. ការកាត់យកប្រាក់ចេញពីបញ្ជីប្រាក់ខែ។ ស្ទើរតែគ្រប់ដីកាទាំងអស់អនុញ្ញាតឲ្យ DCS ទាមទារការឧបត្ថម្ភដោយការដកប្រាក់ពីបញ្ជីប្រាក់ខែរបស់អ្នក ឬតំរូវឲ្យបង់ប្រាក់តាមរយៈ WSSR ។ បើដីកាឧបត្ថម្ភរបស់អ្នកអនុញ្ញាតឲ្យ DCS ធ្វើដូច្នេះ DCS និងសាកល្បងទារប្រាក់ឧបត្ថម្ភនោះដោយការដកប្រាក់ពីបញ្ជីប្រាក់ខែ ។
2. បើអ្នកមិនអាចបង់ប្រាក់បានតាមរយៈការដកប្រាក់ពីបញ្ជីប្រាក់ខែ យើងមានមធ្យោបាយបីយ៉ាងផ្សេងទៀតសំរាប់អ្នកបង់ប្រាក់នោះ ។ សែកផ្ទាល់ខ្លួន មូលប្បទានប័ត្រ មូលប្បទានប័ត្ររ៉ាប់រងដោយធនាគារ ឬសែកបេឡា ។ ចូរផ្ញើគ្រប់សែក និងមូលប្បទានប័ត្រទាំងអស់ទៅ ៖

   WASHINGTON STATE SUPPORT REGISTRY
   PO BOX 45868
   OLYMPIA WA  98504-5868

3. ការផ្ទេរប្រាក់តាមអេឡិចត្រូនិក (EFT) ។ EFT អនុញ្ញាតឲ្យមានការដកប្រាក់ជាស្វ័យប្រវត្តិនៃប្រាក់បង់ឧបត្ថម្ភក្មេងពីគណនីសែកចាយ ឬគណនីសន្សំមួយ ជារៀងរាល់ខែ ។ សំរាប់ព័ត៌មានបន្ថែម, សូមទូរស័ព្ទទាក់ទាងលេខ 800-468-7422 ។
4. អ៊ិនធើណឺត ។ ការបង់ប្រាក់តាមអ៊ិនធើណឺតអនុញ្ញាតឲ្យមានការដកប្រាក់បង់ឧបត្ថម្ភក្មេងពីគណនីសែកចាយ ឬគណនីសន្សំមួយ ។ សម្រាប់ព័ត៌មានបន្ថែម, សូមអញ្ជើញចូលមើលគេហទំព័រ DCS នៅ https://secureaccess.wa.gov។
5. ប័ណ្ណ Credit និងប័ណ្ណ Debit ។ សំរាប់ព័ត៌មានបន្ថែម, សូមអញ្ជើញចូលមើលគេហទំព័រ DCS នៅ https://www.dshs.wa.gov/esa/division-child-support/creditdebit-card-payments ។

បើធនាគាររបស់អ្នកផ្ញើសែកណាមួយរបស់អ្នកត្រឡប់មកវិញ ឬមិនបានទទួលយកការបង់ប្រាក់តាម EFT ឬតាមអ៊ិនធើណឺត ដោយសារមិនមាន ប្រាក់គ្រប់គ្រាន់នៅក្នុងធនាគារ DCS និងទទួលយកការបង់ប្រាក់ទៅអនាគតជាប្រាក់សុទ្ធ មូលប្បទានប័ត្រ សែកបេឡា មូលប្បទានប័ត្ររ៉ាប់រងដោយធនាគារ ឬការកាត់ដកយកប្រាក់ តាមប្រាក់ខែតែប៉ុណ្ណោះ ។

ចូរដាក់បញ្ចូលលេខសំណុំរឿង និងលេខគណនី **IN** ____________________ លើគ្រប់លិខិតបង់ប្រាក់ និងលិខិតឆ្លើយតបទាំងអស់ ។

DCS នឹងមិនឲ្យឥណទានដល់កណនីរបស់អ្នក សំរាប់ប្រាក់ឧបត្ថម្ភកូនទាំងឡាយណា ដែលអ្នកបានបង់ទៅឲ្យនរណាម្នាក់ក្រៅពី WSSR, ក្រៅពីតុលាការកុលសម្ព័ន្ធ ឬក្រៅពីទីភ្នាក់ងារឧបត្ថម្ភកុមារ, ឬក្រៅពីតុលាការ ឬក្រៅទីភ្នាក់ងារឧបត្ថម្ភកុមាររបស់រដ្ឋផ្សេងឡើយ។ DCS នឹងមិនឲ្យឥណទានដល់គណីរបស់អ្នក សំរាប់ប្រាក់ឧបត្ថម្ភកូនទាំងឡាយណា ដែលអ្នកបានបង់ដោយផ្ទាល់ទៅឲ្យភាគីម្ខាងទៀត ដែលមានឈ្មោះក្នុងដីកាឧបត្ថម្ភកូនរបស់អ្នកនោះឡើយ។

បើអ្នកមានមូលហេតុស្របច្បាប់ក្នុងការមិនផ្តល់ប្រាក់សំរាប់ឧបត្ថម្ភកូនរបស់អ្នក ឬបើ DCS មានការភាន់ច្រឡំក្នុងការពាក់ព័ន្ធអ្នកក្នុងរឿង នេះ ជូនដំណឹងមក DCS ជាបន្ទាន់ ។ បើ DCS ជូនដំណឹងអ្នកថាពួកយើងកំពុងព្យួរការប្រមូលកាតព្វកិច្ចឧបត្ថម្ភរបស់អ្នក កាតព្វកិច្ចរបស់អ្នកអាចក្លាយជាអាចប្រមូលបាននៅពេលអនាគត ។ DCS នឹងជូនដំណឹងដល់អ្នកមុននឹងធ្វើចំណាត់ការនេះ ។

ប្រសិនបើអ្នកត្រូវបានគេកម្រិតដល់ ឬកាត់ទោសលើសពីប្រាំមួយខែក្នុងគុក ពន្ធនាគារ ឬមណ្ឌលអប់រំកែប្រែ សេចក្តីបង្គាប់គាំទ្រកូនរបស់អ្នកអាចត្រូវបានកាត់បន្ថយជាបណ្តោះអាសន្ន (បន្ថយថ្ងៃ) ត្រឹម $10 ក្នុងមួយខែ សម្រាប់សេចក្តីបង្គាប់គាំទ្រកុមារម្នាក់ៗ។ អ្នក ឪពុក ឬម្តាយមើលថែរក្សា ឬ DCS អាចស្នើសុំការបន្ថយថ្ងៃបាន។ បើការបន្ថយថ្ងៃអនុវត្តទៅលើករណីរបស់អ្នក។ អ្នកនឹងទទួលបានសេចក្តីជូនដំណឹងពី DCS ដោយពន្យល់លក្ខខណ្ឌនានានៃការបន្ថយថ្ងៃ និងសិទ្ធិរបស់បុគ្គលម្នាក់ៗ ក្នុងការស្នើសុំសវនាការ ប្រសិនបើពួកគេមិនយល់ព្រមតាម។ ចំនួនទឹកប្រាក់នឹងកើតដល់ 50% នៃសេចក្តីបង្គាប់គាំទ្រក្នុងខែទីបួន បន្ទាប់ពីអ្នកត្រូវបានឱ្យចេញ ហើយនឹងកើតឡើងម្តងទៀតដល់ 100% នៃចំនួនទឹកប្រាក់ដើម ក្នុងពេលមួយឆ្នាំបន្ទាប់ពីការឱ្យចេញ។

## កាតព្វកិច្ចឧបត្ថម្ភផ្នែកវេជ្ជសាស្ត្រ

បើដីកាឧបត្ថម្ភកូនរបស់អ្នកតំរូវឲ្យអ្នកផ្តល់ការធានារ៉ាប់រងសុខភាពសំរាប់កូនៗរបស់អ្នក, នោះ DCS នឹងធ្វើសកម្មភាពដើម្បីអនុវត្តកាតព្វកិច្ចរបស់អ្នក។ បើដីកាឧបត្ថម្ភកូនរបស់អ្នកតំរូវឲ្យអ្នកបង់ប្រាក់ឧបត្ថម្ភវេជ្ជសាស្ត្រ, នោះ DCS នឹងបង្កើតគណនីប្រាក់ដុល្លារដែលគេតំរូវឲ្យអ្នកបង់ ហើយនឹងប្រមូលទារប្រាក់ទាំងនោះពីអ្នក ។

1. ប្រាប់ដំណឹងមក DCS ជាបន្ទាន់ បើមានអ្វីប្រែប្រួលទាក់ទងនឹងការផ្តល់កម្រៃធានារ៉ាប់រងសុខភាពរបស់អ្នកសំរាប់កូនៗទាំងឡាយដែលមានឈ្មោះនៅក្នុងដីកាឧបត្ថម្ភកូនរបស់អ្នក។
2. ប្រាក់ឧបត្ថម្ភវេជ្ជសាស្ត្ររួមមានទូវចំណែកសមាមាត្រនៃប្រាក់ចំណាយថ្លៃវេជ្ជសាស្ត្រដែលមិនត្រូវចេញសងវិញ និងចំណែកនៃប្រាក់បុព្វលាភធានារ៉ាប់រង (ការចេញប្រាក់បង់ថ្លៃធានារ៉ាប់រង) បើសិនជាបានតំរូវដោយដីការបស់អ្នក កាលណាការធានារ៉ាប់រងសុខភាពមិនត្រូវបានគេផ្តល់ជូន។

បើដីកាឧបត្ថម្ភក្មេងរបស់អ្នកតំរូវឲ្យឪពុក/ម្តាយជាអ្នកគ្រប់គ្រងកូនផ្តល់ការគ្រប់គ្រងសំរាប់រ៉ាប់រងសុខភាព ឬឲ្យបង់ប្រាក់ចំណាយផ្នែកវេជ្ជសាស្ត្រដែលគ្មានការគ្រប់គ្រង អ្នកអាចដាក់ពាក្យសុំសំរាប់សេវាអនុវត្តន៏ទាមទារគ្រប់បែបយ៉ាង៖

1. សុំឲ្យ DCS អនុវត្តកាតព្វកិច្ចរបស់ឪពុក/ម្តាយជាអ្នកគ្រប់គ្រងកូនដើម្បីផ្តល់ការធានារ៉ាប់រងសុខភាព ។ DCS អាចអនុវត្តនូវកាតព្វកិច្ច ដោយយោលទៅតាមកាលៈទេសៈរបស់សំណុំរឿងអ្នក ។
2. សុំឲ្យ DCS ទាមទារការចំណាយថ្លៃវេជ្ជសាស្ត្រដែលមិនបានបង់ មានរួមទាំង ប្រាក់បង់រង ប្រាក់បង់ដកបង់មុន និងប្រាក់បុព្វលាភដូចមាន ឲ្យនិយមន័យនៅក្នុងក្រម WAC 388-14A-1020 ពីឪពុក/ម្តាយជាអ្នកគ្រប់គ្រងកូន ។

បើដីកាឧបត្ថម្ភក្មេងរបស់អ្នកមិនតំរូវឲ្យឪពុក/ម្តាយជាអ្នកគ្រប់គ្រងកូនផ្តល់ការធានារ៉ាប់រងសុខភាព ចំណែកប្រាក់បុព្វលាភវេជ្ជសាស្ត្រ ឬបង់ប្រាក់សំរាប់ការចំណាយវេជ្ជសាស្ត្រដែលគ្មានការរ៉ាប់រងដូចតាមនិយមន័យនៅក្នុងក្រម WAC 388-14A-1020, អ្នកអាចដាក់ពាក្យសុំទៅ DCS ដើម្បីឲ្យគេពិនិត្យ ដីកាអ្នកសំរាប់លទ្ធភាពធ្វើកំណែប្រែ ឬអ្នកអាចធ្វើបដ្តនាលិខិតសុំធ្វើកំណែប្រែដោយខ្លួនឯង ។

## ប្រភេទនៃឧទ្ទរណ៏

ការប្រជុំប្រឹក្សារដ្ឋបាល ។ ការប្រជុំប្រឹក្សារដ្ឋបាលគឺជាដំណើរការរដ្ឋបាល (មិនមែនតុលាការ) ដែល DCS បានប្រើសំរាប់ដោះស្រាយជំលោះនានា ពន្យល់ អំពីបទបញ្ជាផ្ទៃក្នុង នឹងបំភ្លឺនូវអង្គហេតុនានា ។

1. ការប្រជុំប្រឹក្សារដ្ឋបាលអាចពិនិត្យដីកាឧបត្ថម្ភក្មេងទាំងពីរប្រភេទ ដីកាពីតុលាការ និងដីកាមិនមែនចេញពីតុលាការ ។
2. ការប្រជុំប្រឹក្សារដ្ឋបាលអាចចេញសេចក្តីសំរេចដោយគ្មានការជួបប្រជុំជាមួយយើង ។ បើអ្នកមានការប្រជុំ អ្នកអាចពិភាក្សាសំណុំរឿងរបស់អ្នកជាមួយ ថ្នាក់ដឹកនាំរបស់ DCS ដែលអាចច្រានចោលសេចក្តីសំរេចជាមុនរបស់ DCS ។ ការប្រជុំប្រឹក្សារដ្ឋបាលអាចប្តូរសកម្ម ភាពខ្លះៗដែលធ្វើឡើង ដោយបុគ្គលិករបស DCS យើង ក៏ប៉ុន្តែអង្គប្រជុំនេះមិនអាចប្តូរសកម្មភាពតំរូវដោយច្បាប់បានទេ ។

និតិវិធីវិនិច្ឆ័យ (សវនាការ) ។ សវនាការមួយ ក៏ជាដំណើរការរដ្ឋបាល (មិនមែនតុលាការ) ។ សវនាការគឺមានលក្ខណៈផ្លូវការជាងការប្រជុំ ប្រឹក្សារដ្ឋបាល តែមានលក្ខណក្រៅផ្លូវការជាងសកម្មភាពនៅតុលាការ ។

1. ច្បាប់រដ្ឋផ្តល់ជូនសវនាការសំរាប់ស្ថានភាពមួយចំនួនខ្លះតែប៉ុណ្ណោះ ។ បើ DCS ប្រគល់ជូនអ្នកនូវប្រវេសន៏អ្វីមួយ ប្រវេសន៏នោះប្រាប់អ្នកបើអ្នកមានសិទ្ធិធ្វើសវនាការ ។ ចៅក្រមរដ្ឋបាល (ALJ) ជាអធិបតីនៅពេលធ្វើសវនាការ ។ ចៅក្រម ALJs ទាំងឡាយនោះមិនមែន ជានិយោជិករបស់ DCS ទេ ។
2. នៅពេលធ្វើសវនាការ ចៅក្រម ALJ នឹងពិនិត្យមើលសំណុំរឿងរបស់អ្នក ហើយធ្វើសេចក្តីសំរេចលើជំលោះរបស់អ្នក ។ ដើម្បីបញ្ឈប់ DCS ពីការអនុវត្តន៏ដីកាឧបត្ថម្ភក្មេងរបស់អ្នក អ្នកត្រូវតែសុំធ្វើសវនាការក្នុងរវាង 20 ថ្ងៃ (បើអ្នកទទួលប្រវេសន៏នៅក្នុងរដ្ឋវ៉ាស៊ីនតោន) ឬ ក្នុងរវាង 60 ថ្ងៃ (បើអ្នកទទួលប្រវេសន៏នៅក្រៅរដ្ឋវ៉ាស៊ីនតោន) ក្រោយពីអ្នកទទួលប្រវេសន៏របស់អ្នក ។
    a. អ្នកអាចសុំធ្វើសវនាការមួយក្រោយពីពេលកំរិត 20 ឬ 60 ថ្ងៃ ។ ក៏ប៉ុន្តែ DCS នឹងអនុវត្តដីកាឧបត្ថម្ភ រហូតទាល់តែយើងទទួលសេចក្តីសំរេចពីសវនាការ ។ DCS នឹងមិនចេញសងវិញនូវប្រាក់ទាំងឡាយណាដែលទារបានខណៈពេលរង់ចាំសេចក្តីសំរេចរបស់សវនាការ ។
    b. បើអ្នកស្នើសុំសំរាប់សវនាការ លើសពីម្តងក្នុងមួយឆ្នាំក្រោយពីអ្នកទទួលប្រវេសន៏របស់អ្នក អ្នកនឹងត្រូវបង្ហាញនូវមូលហេតុល្អ (ហេតុផលល្អមួយសំរាប់ធ្វើសម្មើសុំយឺតពេល) ។ ចៅក្រម ALJ អាចមិនទទួលយល់ព្រមលើសម្មើយឺតពេលរបស់អ្នក ។ ក៏ប៉ុន្តែអ្នកអាចមានសិទ្ធិសំរាប់សុំធ្វើកំណែប្រែសំរាប់កាតព្វកិច្ចឧបត្ថម្ភក្មេងរបស់អ្នកនាពេលអនាគត ទោះបីជាអ្នកមិនមានមូលហេតុល្អសំរាប់សម្មើ យឺតពេលក៏ដោយ ។
3. គេនឹងផ្ញើសេចក្តីសំរេចរបស់ចៅក្រម ALJ មួយច្បាប់ជូនអ្នក ។ សេចក្តីសំរេចរបស់ ALJ នឹងមានព័ត៌មានអំពីសិទ្ធិធ្វើសវនាការរបស់អ្នក។
4. បើសមរម្យ DCS នឹងប្រាប់ភាគីទាំងពីរនៅក្នុងដីកាឧបត្ថម្ភរបស់អ្នក កាលណាយើងទទួលសម្មើសុំធ្វើសវនាការ ។ ភាគីទាំងពីរអាចចូលរួមនៅក្នុងសវនាការ ។

បើអ្នកមានសំណួរចំងល់ផ្សេងៗ សូមទាក់ទង៖

DIVISION OF CHILD SUPPORT
PO BOX 11520
TACOMA WA 98411-5520

នៅក្នុង ________________________ តំបន់សេវាទូរស័ព្ទ ____________________

នៅក្រៅ ________________________ តំបន់សេវាទូរស័ព្ទ ______________________

មានសេវាទូរស័ព្ទ TTY/TDD ត្រូវបានបម្រុងសំរាប់មនុស្សគ ឬថ្លង់ផងដែរ។

ចូរមើលទំព័រវីបសៃត្តិ៍របស់យើងនៅ ៖ www.dshs.wa.gov/esa/division-child-support

គ្មានជនណាម្នាក់, ដោយសារពូជសាសន៍, ពណ៌សម្បុរ, សញ្ជាតិដើម, គោលជំនឿ, សាសនា, ភេទ, អាយុ, ឬពិការភាព, គួរត្រូវគេប្រកាន់រើសអើងនៅក្នុងការងារ, សេវាកម្ម, ឬ ទិដ្ឋភាពណាមួយនៃសកម្មភាពនានារបស់កម្មវិធីនេះឡើយ។ ទម្រង់នេះមានបម្រុងជូនជាទ្រង់ទ្រាយផ្សេងៗ ទៅតាមការស្នើសុំ។